ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃព្រហស្បតិ៍ ២ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩*

**សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មានស្តីពី**
**ជំនួបពិភាក្សាការងារ និងជម្រាបលាទាង**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**ជាមួយនិង**
**លោកជំទាវ Angela Corcoran ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា**

ព្រឹកថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារ និងជម្រាបលាពីលោកជំទាវ Angela Corcoran ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្នុងខណៈដែលលោកជំទាវត្រូវបញ្ចប់បេសកកម្មការទូតនៅកម្ពុជា ក៏ដូចជាពិភាក្សាលើការបន្តពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-អូស្ត្រាលី ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងវាយតម្លៃខ្ពស់ចំពោះប្រជាជន និងរាជរដ្ឋាភិបាលអូស្ត្រាលី ដែលប្រទេសអូស្ត្រាលី គឺជាដៃគូដ៏សំខាន់ចូលរួមចំណែកយ៉ាងសកម្ម ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា នាពេលកន្លងមក ។ សមិទ្ធិផលដែលកម្ពុជាទទួលបាន គឺមិនអាចកាត់ផ្តាច់ពីការគាំទ្ររបស់រដ្ឋាភិបាលអូស្ត្រាលី ក៏ដូច លោកជំទាវឯកអគ្គរដ្ឋទូតផ្ទាល់ ក្នុងអាណត្តិការងារការទូតរបស់លោកជំទាវនៅកម្ពុជា ។ ជាក់ស្តែង, អូស្ត្រាលី បានចូលរួមចំណែកយ៉ាងសកម្មក្នុងកម្មវិធីកែទម្រង់ដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងតែអនុវត្តន៍តាមរយៈការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ដោយតម្រង់វិស័យនៃកិច្ចសហប្រតិបត្តិការរបស់អូស្ត្រាលីឱ្យស្របទៅនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនានារបស់កម្ពុជា ជាពិសេស ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ, កិច្ចកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដូចជា ការបណ្តុះបណ្តាលធនធានមនុស្ស សំដៅលើកកម្ពស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ។

នាឱកាសនេះដែរ លោកជំទាវ Angela Corcoran បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរពីក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់កម្ពុជា ក្នុងរយៈពេល ០៣ ឆ្នាំ ដែលលោកជំទាវបានមកបំពេញបេសកកម្មការទូតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានជំរុញឱ្យបេសកកម្មការទូតរបស់លោកជំទាវទទួលបានជោគជ័យដ៏ត្រចះត្រចង់មកដល់ថ្ងៃនេះ ។ លោកជំទាវផ្ទាល់ គឺជាសាក្សីនៃការរីកចម្រើនដ៏ឥតឈប់ឈររបស់កម្ពុជា

នាពេលបច្ចុប្បន្ន ជាមួយកំណើនសេដ្ឋកិច្ចរឹងមាំ ដែលការសម្រេចបានទាំងនេះ គឺកើតមកពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសការដាក់ចេញ និងការអនុវត្តកិច្ចការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ។ លោកជំទាវក៏បានវាយតម្លៃខ្ពស់អំពីចំណងទាក់ទងយ៉ាងរឹងមាំរវាងប្រជាជន និងប្រជាជន (people to people connection) រវាងប្រទេសទាំងពីរ តាមរយៈចំណងមិត្តភាពរវាងប្រជាជនកម្ពុជា និងអូស្ត្រាលី ក៏ដូចជានិស្សិតកម្ពុជាជាច្រើនដែលកំពុងបន្តការសិក្សានៅក្នុងប្រទេសអូស្ត្រាលី ជាដើម ។

ភាគីទាំងពីរ ក៏បានផ្តោតការពិភាក្សាជាសង្ខេបលើកិច្ចសហប្រតិបត្តិការរបស់អូស្ត្រាលីនៅក្នុងតំបន់ និងសកលក៏ដូចជា ការពិភាក្សាអំពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ថ្មីៗរបស់ប្រទេសអូស្ត្រាលីក្រោមកម្មវិធី/គម្រោងអភិវឌ្ឍន៍នានានៅកម្ពុជា ដើម្បីឱ្យកម្មវិធី/គម្រោងអភិវឌ្ឍន៍ទាំងនោះ ឆ្លើយតបទៅតាមអាទិភាព និងតម្រូវការជាក់ស្តែងរបស់ប្រជាជនកម្ពុជា ដូចជាវិស័យកសិកម្ម, ផលិតផលកសិកម្មកែច្នៃ, ខ្សែច្រវ៉ាក់ផលិតផលកសិកម្មដែលមានតម្លៃបន្ថែម, កំណែទម្រង់ផ្សេងទៀតបន្ថែមសំដៅលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា និងទាក់ទាញវិនិយោគិនអូស្ត្រាលី ក៏ដូចជាការបណ្តុះបណ្តាលធនធានមនុស្ស ជាដើម ។

ជាទីបញ្ចប់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ក៏បានជូនពរលោកជំទាវ Angela Corcoran ឱ្យទទួលបានជោគជ័យក្នុងតួនាទីថ្មីរបស់លោកជំទាវនាពេលខាងមុខ និងបានគូសបញ្ជាក់ថា កម្ពុជានឹងបន្តខិតខំលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងមិត្តភាពឱ្យកាន់តែស្អិតរមួតបន្ថែមទៀត ដើម្បីជាឧត្តមប្រយោជន៍សម្រាប់ប្រទេស និងប្រជាជននៃប្រទេសទាំងពីរ **កម្ពុជា-អូស្ត្រាលី** ។